ក-១៧៧ ក
1

# កម្មវិធី

# រាត្រីសិល្បៈ

នៃ



www.elibraryofcambodia.org

ក ១៧៧ ក

# ក្រុមល្ខោនជាតិ

www.elibraryofcambodia.org

ក. 199ក

# សិល្បៈល្ខោនជាសិល្បៈរួម

បានមើលល្ខោនរួចហើយ ... ហើយបើយើងប្រើការគិតបន្តិចទៅនោះ យើងនឹងនឹកឃើញថា មិញៗ អញបានឃើញមនុស្សស្រី-ប្រុសធ្វើ "កាយវិការ" - ឃើញពួកនោះស្លៀកពាក់ "ល្អ" ឬ "ប្លែក" - ឃើញ "ផ្ទាំងសំពត់" លាបពណ៌ ផ្គុំឡើងជាឆាក ឃើញមានភ្លើង "ភ្លឹបភ្លែត" ឬប្រែពណ៌ ... អញបានឮគេ "ច្រៀង" គេ "និយាយ" គេ "គំហក" គេ "ដំអូញ" គេ "សើច" ឬគេ "យំ" លាយនឹងភ្លេង ឬសម្រែក ធ្វើត្រាប់សម្លេងធម្មជាតិ៖ ខ្យល់បក់ ផ្គរលាន់-រន្ទះ ។ល។

នោះទើបយើងនឹកថា៖ "អូ! សិល្បៈល្ខោន ជាសិល្បៈដែលមានសិល្បៈច្រើនមកផ្សំលាយគ្នាទេតើ!" ។

អនុវត្តន៍ទៅតាមការសង្កេតដែលបានថ្លែងមកហើយនេះ ក្រុមល្ខោនជាតិ ស្វះស្វែងរកចំរង់រឿងប្លែកៗ មកជូនលោក-អ្នកនាងមើល ។ ដូច្នេះបានជារឿងទាំងឡាយដែលនឹងចេញលេងក្នុងរាត្រីនេះ មានលក្ខណៈប្លែកៗគ្នាណាស់ ។ រឿងខ្លះច្រើនប្រើមធ្យោបាយ "សិល្បៈកាយវិការ" ពោលគឺ៖ អ្នកលេងល្ខោនត្រូវការតែធ្វើកាយវិការមួយមុខ ដើម្បីបង្ហាញមនោសញ្ចេតនាដែលខ្លួនចង់សំដែងឲ្យអ្នកមើលយល់ ។ "សិល្បៈកាយវិការ" នេះទៀត បែកជាពីរបែបធំៗ បែប "ល្ខោនគ" ដែលច្រើនប្រើសម្រាប់សំដែងការកំប្លែង នឹងបែប "សិល្បៈក្បាច់" ដែលច្រើនប្រើសម្រាប់សំដែងបទកំសត់ ឬបទខ្ពង់ខ្ពស់ ។ មធ្យោបាយដែលមនុស្សអាចធ្វើកើត ក៏បានត្រូវធ្វើជាវេទាយនៃត្រីសិល្បៈយើងនេះ ដូចមានចម្រៀងជាពួក - ចម្រៀងតែឯង - សម្លេងធម្មជាតិ - តន្ត្រី - ដូចមានរបាំ - កាយវិការល្អៗ - ដូចមានសម្លៀកបំពាក់ប្លែកៗ ដែលកើតឡើងបានដោយសិល្បៈករបានប្រើមនោគតិយ៉ាងពិតខំ ។

ទាំងអស់នេះ សរុបសេចក្ដីថា ក្រុមល្ខោនជាតិពង្រីកមធ្យោបាយសិល្បៈរបស់ខ្លួនមិនចេះចប់ មិនចេះហើយទេ ។

www.elibraryofcambodia.org

# ខ្មែរនិងបញ្ចសីលា

រឿងប្រទេសកម្ពុជា គោរពគោលការបញ្ចសីលា មិនមែនជាអាថ៌កំបាំងទេ ពលរដ្ឋខ្មែរម្នាក់ៗ និងមនុស្សក្នុងលោកសឹងតែបានដឹងគ្រប់គ្នា មាគ៌ានយោបាយដ៏ខ្ពង់ខ្ពស់របស់រដ្ឋកម្ពុជានេះ ។ ដូច្នេះការៈយើងឥតត្រូវពន្យល់ពីរឿងនយោបាយបញ្ចសីលានេះឡើយ តែផ្ទុយទៅវិញ យើងមានការៈជូនយោបល់ខ្លះអំពីរឿងល្ខោនរបស់យើងដែលមានចំណងជើងថា "ខ្មែរនិងបញ្ចសីលា" ដូចតទៅ ៗ ដំបូង ៖

ក ) ភូមិខ្មែរ ក្នុងផ្ទៃប្រទេសខ្មែរដែលតាំងជាស្រមោលតាមមធ្យោបាយសិល្បៈឡើង មានអ្នកឈូសឈើ ( ស្រុកយើងសម្បូរឈើ ) អ្នកកូរស្ករ ( ស្រុកយើងមានដើមត្នោត ) ជាងចម្លាក់ព្រះពុទ្ធរូប ( ស្រុកយើងនិយមសិល្បៈនិងព្រះពុទ្ធសាសនា ) ស្រីៗ ស្រិតអង្ករ ( ស្រុកយើងជាស្រុកកសិកម្ម ) និងកញ្ញាស្រាវសូត្រ ( ស្រុកយើង ស្រីៗ ចេះត្បាញ ) ។

ខ ) លោកតាម្នាក់ចូលមកកាន់កាសែតនៅដៃ ( តាមទំនៀមនិយមចាស់ៗ ស្រុកយើងជាតំណាងអ្នកស្រុកដឹងរឿងអ្វីមួយ ហើយតែងយកមកនិយាយប្រាប់មនុស្សម្នាក្នុងស្រុក ) ពានលើរឿង "បញ្ចសីលា" ជារឿងមួយដែលអ្នកទាំងអស់គ្នាបានដឹងជាមុនស្រេច ។

គ ) ល្ខោនពជការមកលេង . . . មែន ! នៅប្រទេសកម្ពុជា ល្ខោនជាតិកើតហើយ ៗ អ្នកស្រុកទៅមើល គឺអ្នកស្រុកអបអរទីនឹងល្ខោនជាតិណាស់ ៗ គេលេងរឿងជាតិ មែន ! ល្ខោនជាតិយើងលេងតែរឿងដែលមានប្រយោជន៍ដល់ជាតិ ។

ឃ ) ល្ខោនគេចេញស្តែង គេឃើញទាដករប្រាំនាក់ ។ ប្រាំនាក់ជារូបនិម្មិតនៃទ្វីបលោកដែលចែកជាប្រាំភាគ ។ ប្រាំនាក់នោះធ្លើយនូវសង្គ្រាម គឺលោកមានសង្គ្រាម ៗ សង្គ្រាមព្រោះអ្វី ? . . . ដណ្តើមទឹកដីគ្នា . . . ចង់លូកលាន់កិច្ចការក្នុងប្រទេសគ្នា . . . មិនគោរពអធិប្បតេយ្យគ្នា . . .

ង ) និងរំលត់សង្គ្រាមបាន ប្រទេសកម្ពុជាដែលមានសម្តេចព្រះឧបយុវរាជ ជារូបនិម្មិត មហាប្រទេសចិនប្រជាមានិត ដែលមានឯកឧត្តមជូ-អេនឡាយ ជារូបនិម្មិត មហាប្រទេសឥណ្ឌា ដែលមានឯកឧត្តមនេរូ ជារូបនិម្មិត សាងបញ្ចសីលា ៗ

www.elibraryofcambodia.org

កស្ត្រខ្មែរអបអរសាទរជាទីបំផុតនូវមាគ៌ានយោបាយបញ្ចសីលានេះ ។

អ្នកមើលល្ខោនអបអរជាទីបំផុតនូវរឿងល្ខោន “ខ្មែរជឿនបញ្ចសីលា” នេះ ។

រឿងបញ្ចសីលានេះ កើតឡើងដោយក្រុមល្ខោនជាតិទាំងអស់គ្នា ដែលបានទទួលបញ្ជាពីរាជរដ្ឋាភិបាលឲ្យលើកជារឿងមួយសម្រាប់លេងទទួលឯកឧត្តមនាយករដ្ឋមន្ត្រីជូ-អេនឡាយ នៅថ្ងៃ២វិច្ឆិកា ឆ្នាំ១៩៥៦ ។



www.elibraryofcambodia.org

រូបថតនេះធ្វើឲ្យអ្នកមើលស្គាល់ភ្លាមថានេះជារូបលោកហ៊ុ · ឈឿន ដែលល្បីល្បាញត្រង់ចេះកំប្លែងថ្លៃថ្នូរ-មានទឹកចិត្តទូលំទូលាយ ទាំឲ្យលោកមានមិត្តច្រើននឹងមានគំនិត “ឈ្លាស” ដើម្បីផ្តល់ផលប្រទេសកម្ពុជា នូវសិល្បៈល្ខោនសម័យថ្មីតាំងពីលោកនៅជាសិស្សឯអនុវិទ្យាល័យរហូតដល់លោកធ្វើជាគ្រូចកធ្វើមេជំពង់ ។

លក្ខណសម្បត្តិទាំងនេះ បានទាញអារម្មណ៍រាជរដ្ឋាភិបាល , រាជរដ្ឋាភិបាលក៏បានតាំងលោកជា ៖

## ចាងហ្វាងសាលាខេមរតូរ្យតន្ត្រីនិងល្ខោនជាតិ

តាំងពីថ្ងៃ២៧តុលា ឆ្នាំ១៩៥៥

# កិច្ចការអ្នកស្រែ

សិល្បៈល្ខោនជាកញ្ចក់សម្រាប់ឆ្លុះសង្គមមនុស្ស ។ បើយើងយកល្ខោនទៅឆ្លុះមើលសង្គមខ្មែរសព្វថ្ងៃ យើងនឹងឃើញអ្វីខ្លះ ?

ចិត្តជាកូនខ្មែរ មិនភ្លេចគុណអ្នកស្រែទេ ហើយម្យ៉ាងទៀតអ្នកណាក៏គង់ដឹងថា ប្រជាជនខ្មែរមានភាគច្រើនជា "កសិករ" ។ ពាក្យថា "កសិករ អ្នកស្រែ" នាំយើងនឹកឃើញទៅដល់ទឹកភ្លៀង ដល់បញ្ហាទឹកភ្លៀង, ដល់រដូវកំរ, ដល់ទុក្ខដែលកើតឡើងដោយគ្មានភ្លៀង, ដល់ភ្លៀងជំបូង - ដល់សេចក្ដីសប្បាយ និងទឹកសិល្បៈដែលកើតឡើង ពេលមានភ្លៀងជំបូង . . .

" កិច្ចការអ្នកស្រែ " គឺការភ្ជួរ, ការរាស់ . ការដាំ , ការច្រូត , ការទូលបាយឲ្យប្ដី . ការបោក , ការបែន , ការជំពាក់បំណុល . . .

" កិច្ចការអ្នកស្រែ " គឺគោ [illegible] ហ៊ុង . . គឺចាប, កណ្ដាប . . . . គឺយប់ . . . គឺចម្រៀង, កាព្យឃ្លោង . . . គឺ . . . បរិយាកាសដែលចិត្តកូនខ្មែរធ្លាប់ស្គាល់រូបឃើញ ហើយនាំឲ្យរំភើបចិត្ត ។

របៀបលេង រឿង ក៏ប្រើរបៀបប្លែក ដែលបន្ទំតួលដែលមាន " រូបកាយ " " សម្លេង " ជាមនុស្ស ស្រសោះឲ្យក្លាយទៅជាដើមឈើ, ទៅជាផ្កា, ទៅជាខ្យល់, ទៅជាភ្លៀង, ទៅជាភ្លើង, ទៅជាសត្វគ្រប់បែប, គ្រប់យ៉ាង .. តាមមធ្យោបាយសិល្បៈ តើមនុស្សមានអ្វីជាធ្វើមិនកើត !

រឿង " កិច្ចការអ្នកស្រែ " នេះកើតឡើងដោយក្រុមល្ខោនជាតិរៀបចំក្នុងឋានៈជានិស្សិត រៀនខាងសិល្បៈល្ខោន សម្រាប់លេងជូនក្រុមបេសកកម្មវប្បធម៌ ចេកូស្លូវ៉ាគី ដែលគេបានមកប្រទេសយើងនៅចុងខែមករា ១៩៨៧ ។

www.elibraryofcambodia.org


www.elibraryofcambodia.org

នេះជារូបថតនៃវង្សត្រកូលមួយដែលបិតានឹងមាតាមាននាមថា "សិល្បៈល្ខោន" ។ របៀបថតរួមផ្តុំនេះសរសេចក្ដីឲ្យ ឃើញថាសមាជិកវង្សត្រកូលដ៏ធំនេះរាប់អានស្រឡាញ់គ្នា មិនតិចជាងការស្រឡាញ់រវាងបងប្អូនបង្កើតឡើយ ។

# រឿង «ស្នេហាជាតិ»

សេចក្ដីស្នេហាជាតិ ដែលល្ខោនជាតិយើងនឹងចេញលេង គឺសំដៅត្រង់ចិត្តស្នេហាជាតិរបស់ខ្មែរ ។ ពាំងនាងលើកឡើង យើងឃើញទង់ជាតិ·ទង់សាសនា·ទង់ជ័យរាជាធិបតេយ្យ (ជាតិ·សាសនា-មហាក្សត្រ) តែប្រវត្តិសាស្ត្រមិននៅនឹងមួយកន្លែងទេ...ជាតិខ្មែរ មានកាលចុះទាបឱន-មានកាលឡើងខ្ពស់ត្រដែត ដូចបានទុកក្នុងក្រាំងលោកតាបុស្សនៃល្ខោនយើងនេះ ។

ទង់ជាតិខ្ពស់ ជាតិខ្មែររុងរឿង!

ទង់ជាតិធ្លាក់ ជាតិខ្មែរទាបឱន!

ចុះបើជាតិខ្មែរទាបឱន ពលរដ្ឋខ្មែរត្រូវធ្វើដូចម្ដេច?

នៅសតវត្សទី១៥ លោកចៅហ្វាយស្រុកមឿងនឹងគីរិយាសុខចិត្តបូជាជីវិត ដើម្បីស្នេហាជាតិ កើតមាននៅក្នុងចិត្តខ្មែរទាំងអស់គ្នា ហើយខ្មែរធ្វើការដើម្បីជាតិបានច្រើន ៗ

ប្រវត្តិសាស្ត្រជាប្រទេះកង់ ។ ចុងសតវត្សទី១៩ ប្រទេសកម្ពុជាទាបឱនម្ដងទៀត ។ ព្រះករុណាព្រះបាទសីហនុព្រះអង្គក៏បាន[illegible]សេចក្ដីស្នេហាមាតុភូមិឲ្យបានជ្រួតជ្រាបក្នុងចិត្តប្រជានុរាស្ត្រ ។ ហើយនៅក្នុងលើកនេះទៀត ទង់ជាតិបានបក់រវិចដោយសេរីភាពពេញលំហអាកាសនៃប្រទេសកម្ពុជា ។

សម្ដេចព្រះឧបយុវរាជព្រះអង្គបានបង្ហាញឲ្យឃើញជាក់ស្ដែង ដែលមានតាម៉ឺន-ទាហាន-ពាណិជ្ជករ-អ្នកស្រែចំការ·យុវជន-ជីវពល-នារីក្លាហាន តាមហែព្រះអង្គផង ។

ដោយសម្ដេចជារូបនិមិត្តនៃចិត្តស្នេហាជាតិ ប្រទេសខ្មែរក៏ចេះតែមានដំណើររលឿនទៅមុខទៀត ៗ

រឿងស្នេហាជាតិនេះ បានចាប់កំណើតឡើងដើម្បីនឹងរៀបចំទទួលឯកឧត្តមនាយករដ្ឋមន្ត្រី

យ៉ូហ៊ីស្សប - ស៊ីរ៉ាង គៀវីតាស៍.

នៅថ្ងៃ ២៣ ខែមេសា ឆ្នាំ ១៩៥៧

# សិល្បៈល្ខោនរួមមនុស្ស

នឹងសាងជាស្នាដៃសិល្បៈល្ខោនមួយបាន លុះត្រាតែមានសហការយ៉ាងជិតស្និទ្ធបំផុតរវាងសិល្បៈករទាំងឡាយនេះ៖ អ្នកនិពន្ធ អ្នកបង្ហាត់រឿង នាដការិនី និងនាដករ-អ្នកកាត់តែងសំលៀកបំពាក់-អ្នកលំអឆាក អ្នករៀបចំភ្លើង រហូតដល់អ្នកចាត់ចែងការទូទៅក្នុងរោងល្ខោន ។

ពាក្យមនុស្សធម្មតាស្ទើរតែរកគ្មាន ដើម្បីអធិប្បាយឲ្យចំអំពីការចាំបាច់ នៃកិច្ចសហការរវាងសិល្បៈករទាំងនោះ ដើម្បីអធិប្បាយអំពីសន្ទានចិត្តនិងសន្ទានគំនិតតែមួយ ដែលសិល្បករទាំងនោះត្រូវមាន ដើម្បីយកមកពូតធ្វើជាដុំឡើង ឲ្យទៅជាមូលដ្ឋាន.ហាងវត្ថុសិល្បៈ ។ ការមានចិត្តនិងគំនិតលាយគ្នាតែមួយបែបនេះហើយ ដែលជាអាថ៌កំបាំងនិងជាកម្លាំងនៃសិល្បៈសម្រាប់ទៅទាញចិត្តជនសាមញ្ញ ឲ្យមករួមលាយចូលជាមួយផង ។

ដូច្នេះ វត្ថុសិល្បៈនឹងកើតឡើងបាន លុះត្រាតែមនុស្សមានសេចក្ដីយោគយល់ស្រឡាញ់គ្នាជាទីបំផុត, ដូច្នេះ វត្ថុសិល្បៈជាគ្រឿងនាំមនុស្សឲ្យយោគយល់ស្រឡាញ់គ្នា ហើយក្នុងករណីនេះ សិល្បៈជាមធ្យោបាយ ដើម្បីដឹកនាំមនុស្ស ឲ្យទៅរកសេចក្ដីសុខក្សេមក្សាន្តពេញ ។

www.elibraryofcambodia.org

រឿងដ៏ដូនដ៏តាខ្មែរយើង ល្បីល្បាញខាងសិល្បៈជារឿងអ្នកណាក៏អាចដឹងដែរ ការលើករឿងនេះមកអធិប្បាយទៀត អាចទៅជាបទច្រំដែល តែរឿងដែលយើងត្រូវនិយាយ ត្រូវរំឭកគ្នា គឺរឿងដែលណែនាំបងប្អូនខ្មែរសម័យនេះ ឲ្យនិយមនឹងប្រព្រឹត្តសិល្បៈ ។

ផលប្រយោជន៍ដែលអាចកើតពីសិល្បៈ មានច្រើនជាអនេក តែក្នុងទំព័រនេះ យើងចុចតែផលមួយមុខដែលយើងបានថែងមកហើយ គឺផលដែលថា៖

សិល្បៈល្ខោនរួមមនុស្ស

# អ្នកមើលអាចជួយអ្នកលេងបានដូចម្ដេច?

រឿងនាយនេះ ជារឿងពិបាកអធិប្បាយជូនជាទីបំផុត ។ ពីព្រោះអ្នកមើលអាចនឹកស្មានថា : " ស្អី! ពួកល្ខោនគិតតែលេងទៅ ចាំបាច់មកណែនាំអ្នកមើលធ្វើអ្វី? សំបុត្រទិញហើយ គេចង់ធ្វើដូចម្ដេចធ្វើទៅ ។

រីឯការពិត សេចក្ដីតទៅ គ្រាន់តែជាការអង្វរចិត្តអ្នកមើលឲ្យជួយអ្នកលេងល្ខោនប៉ុណ្ណោះ ។ ជួយបានដូចម្ដេច?...

– ដំបូងគឺមកឲ្យទាន់ម៉ោង ដើម្បីជៀសវាងពេលដើរខ្ទាត់ខ្ទែងក្នុងទីងងឹត ពេលដែលល្ខោនចាប់លេងហើយ ។

ត្រង់នេះត្រូវបញ្ជាក់ថា រឿងដំបូងនៃល្ខោនសម័យថ្មី ច្រើនតែមានសារៈសំខាន់បំផុត ព្រោះនៅឆាកដំបូងនេះហើយដែលអង្គរឿងចាប់កំណើតឡើង ។ ចុះបើយើងមិនបានដឹងដើមរឿង ឬ យើងបានរំខាន គេមិនឲ្យស្ដាប់ដើមរឿងបាន...

– ពេលល្ខោនកំពុងតែសំដែង សូម [illegible] ស្ងាត់ជាទីបំផុត មិនតែប៉ុណ្ណោះ ត្រូវលែងអារម្មណ៍ចិត្តគំនិតឲ្យទៅតាមរឿងទៀត ព្រោះហើយនៅអង្គុំនេះ អាចបញ្ជាក់បានថា បើយើងធ្វើបាន-ត្រូវជៀសវាង នាំក្មេងដែលមិនទាន់ដឹងក្ដីឲ្យទៅមើលល្ខោន បែបនេះ

– រឿងទីបីជារឿងពិបាកបន្តិច តែណ្ហើយ! យើងសូមបិទមួយភ្លែតទៀតចុះ គង់រឿងល្ខោនទាំងមួយៗ មិនលែងមានអង្គុំកំប្លែង! អង្គុំសត់ - ឬអង្គុំខ្វះ ដែលមានសំដីពីរោះក្បោះក្បាយដែលត្រូវការ ស្ដាប់គង់ប្រង... អ្នកមើលមានករណីយកិច្ច - បើធ្វើបាន - ផ្ដួលមនោសញ្ចេតនាឲ្យទៅតាមទឹករឿងផង ។

ចាំងនេះ - សូមបញ្ជាក់មួយទៀត - គ្រាន់តែជាការជំរាបថា អ្នកមើលអាចជួយអ្នកលេងបានយ៉ាងស្រួលដូចនេះឯង ។

មើលរាត្រីសិល្បៈនេះហើយ ខ្ញុំចង់ជួយក្រុមល្ខោនជាតិ ។ តើខ្ញុំត្រូវធ្វើដូចម្ដេច? ត្រូវបបួលគ្នាមកមើលឲ្យបានច្រើនទៀត - ជួយឃោសនាទូទៅឧត្ដមគតិល្អ ជួយឲ្យយោបល់ដើម្បីកែសេចក្ដីចំរើន គឺជួយដូចល្ខោននេះ ជាល្ខោនលោកអ្នកនាងដែរ ........................

www.elibraryofcambodia.org

ពាក្យសច្ចារបស់ក្រុមល្ខោនជាតិ

ចំរើនការងារសិល្បៈល្ខោន

ថ្វាយចំពោះ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ៗ

www.elibraryofcambodia.org

និង សម្ដេចព្រះមហាក្សត្រិយានី

ដើរតាមមាគ៌ា សម្ដេចព្រះឧបយុវរាជ

បម្រើ ប្រជាជាតិខ្មែរ គ្រប់ជាន់ថ្នាក់ដោយ

តម្លៃដ៏ខ្ពង់ខ្ពស់នៃសិល្បៈខ្មែរ ៗ

រោងពុម្ពរស្មី លេខ៥៣ រុក្ខវិថីព្រះបាទសីហនុ ភ្នំពេញ

www.elibraryofcambodia.org